ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ០០៧ សហវ

រាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០០៧

# សារាចរណែនាំ

## ស្តីពី

## ការអនុវត្តគោលនយោបាយនៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ

ដោយអនុលោមតាមអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០០៦ ស្តីពីកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំទីចាត់ការគយ និង រដ្ឋាករ និងធ្វើការកំណត់ដូចខាងក្រោម :

១-កំណត់ជ្រើសរើសជាដំណាក់កាលដំបូងនូវសូចនាករហានិភ័យ (Risk Indicators) ចំនួន ២៨ ដូចមានចែងក្នុងឧបសម្ព័ន្ធ ១ នៃសារាចរណែនាំនេះ។ សូចនាករទាំងនេះជាមូលដ្ឋានដើម្បីកំណត់ប្រភេទនីតិបុគ្គលជា ០៣ កំរិតគឺ កំរិតហានិភ័យខ្ពស់ កំរិតហានិភ័យមធ្យម និងកំរិតហានិភ័យទាប ដោយត្រូវរក្សាសូចនាករហានិភ័យទាំងនេះជាការសម្ងាត់វិជ្ជាជីវៈ។ សូចនាករហានិភ័យទាំង ២៨ ចែកចេញជាបីក្រុមដូចតទៅ :

- -ក្រុម A : ផ្នែកស្ថាប័ន និងហិរញ្ញវត្ថុ : មាន ៩ សូចនាករ
- -ក្រុម B : ផ្នែកបែបបទគយ និងអនុលោមភាព : មាន ១១ សូចនាករ
- -ក្រុម C : ផ្នែកសវនកម្មក្រោយបញ្ចេញទំនិញពីគយ និងការបង្ក្រាប : មាន ៨ សូចនាករ

២-កំណត់អោយប្រើប្រាស់នូវសេចក្តីណែនាំប្រតិបត្តិសម្រាប់កំណត់ប្រភេទបុគ្គល (Operational Manual for Profiling) ដូចមានចែងក្នុងឧបសម្ព័ន្ធ ២ នៃសារាចរនេះ ។

៣-កំណត់អោយប្រើប្រាស់នូវប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (Trader's Credibility Management System: TCMS) នៅទីចាត់ការគយនិងរដ្ឋាករ ស្របតាមសេចក្តីណែនាំប្រតិបត្តិ (Operating Manual) ដូចមានក្នុងឧបសម្ព័ន្ធ ៣ នៃសារាចរនេះ ។

៤-ប្រសិនបើមានព័ត៌មានពីប្រភពផ្សេងៗដែលអាចគួរជឿទុកចិត្តបាន ទីចាត់ការគយនិងរដ្ឋាករ អាចធ្វើការវាយតម្លៃ និងពិនិត្យលទ្ធភាពកំណត់កម្រិតហានិភ័យឡើងវិញ។

៥- ទីចាត់ការគយនិងរដ្ឋាករអាចស្នើសុំកែសម្រួល ឬស្នើសុំបំពេញបន្ថែមជាបន្តបន្ទាប់នូវសូចនាករហានិភ័យតាមលទ្ធភាពព័ត៌មាន ក្នុងគោលបំណងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រងហានិភ័យនេះនាដំណាច់ឆ្នាំនីមួយៗ។

ក្នុងករណីមានការកែសម្រួល ឬបំពេញបន្ថែម ទីចាត់ការគយនិងរដ្ឋាករ ត្រូវស្នើសុំដើម្បីចាត់ចែងបញ្ចូលទិន្នន័យ និងលទ្ធផលនៃការវាយតម្លៃ ថ្មីនេះទៅក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យ ។

៦-ទីចាត់ការគយនិងរដ្ឋាករ ត្រូវសម្របសម្រួលជាមួយស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីកសាងនូវលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យ (Risk Selectivity Criteria) ពីប្រព័ន្ធទិន្នន័យដែលមានស្រាប់ ឬអាចរកបាន ដើម្បីស្នើសុំដាក់បញ្ចូលឱ្យទាន់ពេលវេលាទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (ASYCUDA) ។

៧-ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ និងជាប្រធានក្រុមសម្របសម្រួលអន្តរស្ថាប័ននៃកិច្ចសម្រួលពាណិជ្ជកម្មតាមរយៈការគ្រប់គ្រងហានិភ័យ ត្រូវកំណត់ពីពេលមួយទៅពេលមួយនូវមន្ត្រីរាជការមានសមត្ថកិច្ចដែលអាចមានសិទ្ធ និងភារកិច្ចទទួលជាអ្នកគ្រប់គ្រង (Administrator) ឬជាអ្នកប្រើប្រាស់ (User) សូចនាករហានិភ័យ និងការវាយតម្លៃនានាដែលមានចែងក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យនេះទាំងស្រុង ឬមួយផ្នែក។ ក្នុងករណីចាំបាច់ ការផ្សព្វផ្សាយ ឬផ្តល់ព័ត៌មានពាក់ព័ន្ធ ត្រូវមានការអនុញ្ញាតដោយឡែកជាមុនពីប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយនិងរដ្ឋាករ ។

ទទួលបានសារាចរណែនាំនេះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករត្រូវសម្របសម្រួលចាត់ចែងអនុវត្តន៍ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន**
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
  "ដើម្បីជូនជ្រាបជាព័ត៌មាន ឬ/និងដើម្បីសហការ"
- រាជកិច្ច
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ